ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៦៤៩៦......អពដ

ថ្ងៃសុក្រ ៤កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារកាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ-អាករ សម្រាប់ការិយបរិច្ឆេទជាប់ពន្ធប្រចាំខែមេសា ឆ្នាំ២០១៨

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដោយកាលបរិច្ឆេទផុតកំណត់នៃការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ-អាករគ្រប់ប្រភេទប្រចាំខែមេសា ត្រូវចំថ្ងៃឈប់សំរាកចុងសប្តាហ៍ ហេតុនេះ ដើម្បីសម្រួលដល់អ្នកជាប់ពន្ធមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំលិខិតប្រកាសបង់ពន្ធប្រចាំខែ អគ្គនាយកដ្ឋានពន្ធដារ សម្រេចពន្យារកាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ ប្រចាំខែមេសា ឆ្នាំ២០១៨ រហូតដល់ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨។ សម្រាប់ខែបន្តបន្ទាប់ ត្រូវអនុវត្តជាធម្មតា ដូចមានចែងក្នុងលិខិតជូនដំណឹងលេខ ៩៣១ អពដ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ការពន្យារកាលបរិច្ឆេទដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ-អាករនេះ នឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន។

Collection by VCAT Professional Consultant

អគ្គនាយកដ្ឋានពន្ធដារ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh